ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## របៀបតាមដានវឌ្ឍនភាពសំណើសុំសេវាសាធារណៈ សំណើសុំចុះកិច្ចព្រមព្រៀង ឬទូទាត់ថវិកាពី ប.ស.ស. និងការដាក់ពាក្យទៅធ្វើការនៅក្រៅប្រទេស

ដើម្បីធានានូវគណនេយ្យភាព តម្លាភាព និងសុចរិតភាពនៃការផ្តល់សេវាសាធារណៈរបស់ក្រសួង, ការស្នើសុំចុះកិច្ចព្រមព្រៀងមូលដ្ឋានសុខាភិបាលជាមួយ ប.ស.ស., សំណើសុំទូទាត់ថវិកាជូនមូលដ្ឋានសុខាភិបាលជាដៃគូ ប.ស.ស. និងការដាក់ពាក្យស្នើសុំចេញទៅធ្វើការនៅក្រៅប្រទេស នាពេលកន្លងមក ក្រសួងបានដាក់ឱ្យដំណើរការនូវប្រព័ន្ធតាមដានវឌ្ឍនភាពសំណើសុំសេវាសាធារណៈ ឬពាក្យស្នើសុំនានា (Tracking System) ដែលអនុញ្ញាតឱ្យអ្នកស្នើសុំទាំងអស់អាចតាមដាននូវវឌ្ឍនភាពសំណើសុំរបស់ខ្លួនថាកំពុងស្ថិតនៅក្នុងដំណាក់កាលណាមួយ។

ក្នុងន័យនេះ ដើម្បីបង្ការការឆបោក ឬការមិនទទួលខុសត្រូវរបស់បុគ្គលណាមួយ ជាថ្មីម្តងទៀត ក្រសួងសូមជូនដំណឹង និងលើកទឹកចិត្តដល់សាធារណជន កម្មករនិយោជិត និយោជក និងម្ចាស់មូលដ្ឋានសុខាភិបាល សូមបន្តប្រើប្រាស់ប្រព័ន្ធតាមដានវឌ្ឍនភាពសេវាសាធារណៈ ឬពាក្យស្នើសុំនានា (Tracking System) នេះ ឱ្យបានទូលំទូលាយ ដោយអនុវត្ត ដូចខាងក្រោម៖

១-នៅពេលស្នើសុំសេវានានា ត្រូវទាមទារលេខកូដតាមដានសេវាសម្រាប់តាមដានសំណើរបស់ខ្លួន។

២-ក្រោយទទួលបានលេខកូដ ត្រូវវាយបញ្ចូលលេខកូដនេះ នៅក្នុងគេហទំព័រ https://tracking.mlvt.gov.kh/ ដើម្បីតាមដានវឌ្ឍនភាពសំណើរបស់ខ្លួនថាកំពុងស្ថិតនៅក្នុងដំណាក់កាលណា។

សម្រាប់ព័ត៌មានបន្ថែម សាធារណជន កម្មករនិយោជិត និយោជក និងម្ចាស់មូលដ្ឋានសុខាភិបាល អាចទំនាក់ទំនងមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈប្រព័ន្ធ Hotline លេខ "១២៨៦" ឬ "១២៩៧" ក្រុមតេលេក្រាម "សម្រាប់និយោជក" (https://t.me/EmployerChat) និងក្រុមតេលេក្រាម "សម្រាប់កម្មករនិយោជិត" (https://t.me/KhmerWorkerChat) ដែលអាចភ្ជាប់តាមរយៈការស្កេន QR Code ខាងក្រោម។

ជាមួយគ្នានេះ សាធារណជន កម្មករនិយោជិត និយោជក និងម្ចាស់មូលដ្ឋានសុខាភិបាល ដែលមានការមិនពេញចិត្ត ឬមានមន្ទិលសង្ស័យ ឬមានបំណងចង់ប្តឹងបុគ្គលណាមួយ ក៏អាចដាក់ពាក្យបណ្តឹងអនាមិកតាមរយៈគេហទំព័រ https://feedback.mlvt.gov.kh ផងដែរ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ជាពិសេស កម្មករនិយោជិត និយោជក និងម្ចាស់មូលដ្ឋានសុខាភិបាល ជ្រាបជាព័ត៌មាន។

ថ្ងៃ អង្គារ ១កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២៤

សម្រាប់និយោជក

សម្រាប់កម្មករនិយោជិត

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩